

# តើជំងឺផ្តាសាយធំគឺជាអ្វី?

ជំងឺផ្តាសាយធំ ឬជំងឺគ្រុនផ្តាសាយ គឺជាជំងឺឆ្លងដែលអាចប៉ះពាល់ដល់សុខភាពអ្នន់ធ្ងរ។

ជំងឺផ្តាសាយធំគឺជាជំងឺធ្ងន់ធ្ងរណាស់។ វាអាចបង្កឱ្យមនុស្សធ្លាក់ខ្លួនឈឺត្រូវសម្រាកព្យាបាលនៅមន្ទីរពេទ្យ ជាពិសេសនោះគឺសម្រាប់កុមារដែលមានអាយុក្រោម 5 ឆ្នាំ មនុស្សដែលមានអាយុលើសពី 65 ឆ្នាំ ស្ត្រីមានផ្ទៃពោះ និងអ្នកដែលមានជំងឺទឹកនោមផ្អែម ជំងឺសួត ឬជំងឺបេះដូង។

ប្រភេទមេរោគគ្រុនផ្តាសាយដែលមានការរីករាលដាលជារៀងរាល់ឆ្នាំ គឺមានលក្ខណ:ខុសគ្នា។ ដោយសារតែបញ្ហានេះហើយ ជារៀងរាល់ពេលអ្នកជំនាញត្រូវការផ្លាស់ប្តូរវ៉ាក់សាំង ដើម្បីឱ្យប្រាកដថា វ៉ាក់សាំងផ្តល់នូវការការពារត្រឹមត្រូវដល់រាងកាយរបស់អ្នក។

នេះហើយគឺជាមូលហេតុដ៏សំខាន់សម្រាប់អ្នកក្នុងការចាក់វ៉ាក់សាំងបង្ការជំងឺគ្រុនផ្តាសាយធំជារៀងរាល់ឆ្នាំ។

ថ្នាំបង្ការជំងឺផ្តាសាយធំនេះ គឺងាយរកបាន ហើយឥតគិតថ្លៃឡើយសម្រាប់ជនគ្រប់រូបនៅរដ្ឋឃ្វីនស្លែនក្នុងឆ្នាំ 2024។

ប្រសិនបើអ្នកបានចាក់វ៉ាក់សាំងរួច នោះអ្នកអាចកាត់បន្ថយឱកាសនៃឆ្លងជំងឺផ្តាសាយធំបាន។

វ៉ាក់សាំងបង្ការជំងឺគ្រុនផ្តាសាយធំមានសុវត្ថិភាព និងមានប្រសិទ្ធភាព។ វ៉ាក់សាំងជំងឺផ្តាសាយនេះជួយអ្នកប្រយុទ្ធប្រឆាំងនឹងមេរោគ

និងជួយបញ្ឈប់ពីការឆ្លងរាលដាលទៅកាន់មនុស្សផ្សេងទៀត។ប្រសិនបើអ្នកបានឆ្លងមេរោគគ្រុនផ្តាសាយ ការដែលទទួលបានការចាក់វ៉ាក់សាំងរួចអាចជួយការពារអ្នកពីការធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរ។

## រោគសញ្ញា

ជាធម្មតា អ្នកនឹងមានរោគសញ្ញាជំងឺគ្រុនផ្តាសាយធំចាប់ពី 1 ថ្ងៃទៅ 3 ថ្ងៃក្រោយពេលឆ្លងមេរោគរួច ឬបានប៉ះពាល់នឹងមេរោគនេះ។ *រោគសញ្ញាមួយចំនួនមានដូចជា៖*



គ្រុនក្តៅ



ឈឺបំពង់ក



ក្អកស្ងួត



ឈឺក្បាល



ឈឺសន្លាក់ ឬសាច់ដុំ



អស់កម្លាំង



ចង្អោរ (មានអារម្មណ៍ថាឈឺ) ក្អួត

ឬរាគ (រាគហូរដូចទឹក និងរាគលាមជាសំបោរ)

ភាគច្រើនបំផុតកើតឡើងទៅលើកុមារ។



រវើរវាយ ដង្ហក់ (ដកដង្ហើមខ្លីៗ)

កើតឡើងនៅក្នុងចំណោមមនុស្សចាស់។

## របៀបឆ្លងរាលដាលនៃជំងឺផ្តាសាយធំ

មេរោគគ្រុនផ្តាសាយធំអាចឆ្លងបាននៅពេលដែលអ្នកជំងឺក្អក ឬកណ្តាស់ ដោយមិនបានខ្ទប់មាត់ និងច្រមុះរបស់ពួកគេដោយប្រើកែងដៃ ឬក្រដាសជូតមាត់។ ជំងឺនេះក៏អាចឆ្លងបានដែរ នៅពេលអ្នកប៉ះផ្ទៃ (កន្លែង) ដែលកខ្វក់ដែលមានមេរោគ ហើយក្រោយមកទៅប៉ះមាត់ ច្រមុះ ឬភ្នែករបស់អ្នក។

## វិធីបង្កាពីការឆ្លងរីករាលដាលនៃជំងឺផ្តាសាយ

**ខាងក្រោមនេះគឺជាជំហានទាំង 7 ដើម្បីជួយប្រយុទ្ធប្រឆាំងនឹងជំងឺផ្តាសាយធំ៖**

ចាក់វ៉ាក់សាំងបង្កាជំងឺគ្រុនផ្តាសាយធំជារៀងរាល់ឆ្នាំ។

លាងដៃរបស់អ្នកជាមួយនឹងសាប៊ូ និងទឹក។ ឬក៏ប្រើទឹកលាងដៃដែលមានជាតិអាល់កុល។

ប្រសិនបើអ្នកមិនស្រួលខ្លួន ចូរស្នាក់នៅក្នុងផ្ទះ។ ជៀសវាងទៅប៉ះពាល់ជាមួយនឹងអ្នកផ្សេងទៀត។

យកកន្សែង ឬកែងដៃរបស់អ្នកខ្ទប់មាត់ ឬច្រមុះនៅពេលក្អក និងកណ្តាស់។

នៅឱ្យឆ្ងាយពីអ្នកដែលក្អក និងកណ្តាស់សាចម្ងាយ 1.5 ម៉ែត្រ។

កន្សែងសើមស្អាតទៅលាងសម្អាតកន្លែង (ផ្ទៃដែលរាបស្មើ) ដែលប្រើប្រាស់រៀងរាល់ថ្ងៃ។ ហាលកន្សែងឱ្យស្ងួតក្រោយពេលប្រើរួច។

កុំចែក ឬក៏ប្រើរបស់របរ ឬអ្វីៗដែលប៉ះនឹងមាត់ ឬច្រមុះ។

## ការព្យាបាល

វិធានការណ៍ថែទាំខ្លួនអាចជួយគ្រប់គ្រងរោគសញ្ញានៃជំងឺផ្តាសាយ រួមមាន ៖

- សម្រាកឱ្យបានច្រើន
- ទទួលទានទឹកឱ្យបានច្រើន។
- លេបថ្នាំបំបាត់ការឈឺចាប់ ដើម្បីជួយកាត់បន្ថយរោគសញ្ញារបស់អ្នក។

ប្រសិនបើអ្នកមានហានិភ័យខ្ពស់ក្នុងការធ្លាក់ខ្លួនឈឺខ្លាំង វេជ្ជបណ្ឌិតរបស់អ្នកអាចផ្តល់ជូនអ្នកនូវថ្នាំប្រឆាំងនឹងវីរុស សូមនិយាយជាមួយវេជ្ជបណ្ឌិតរបស់អ្នកប្រសិនបើអ្នកមិនស្រួលខ្លួន។

## កន្លែងចាក់វ៉ាក់សាំងបង្កាជំងឺគ្រុនផ្តាសាយធំរបស់អ្នក

អ្នកអាចចាក់វ៉ាក់សាំងបង្ការជំងឺគ្រុនផ្តាសាយធំពីគ្រូពេទ្យទូទៅ គ្លីនិកចាក់ថ្នាំការពាររោគសហគមន៍ ឬឱសថស្ថាន។ វ៉ាក់សាំងឥតគិតថ្លៃសម្រាប់មនុស្សមួយចំនួន។ ដើម្បីដឹងថាតើអ្នកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីទទួលបានឬអត់នោះ សូមទាក់ទងទៅកាន់គ្រូពេទ្យទូទៅ ឬអ្នកផ្តល់វ៉ាក់សាំងបង្ការជំងឺរបស់អ្នក។

## ត្រូវការព័ត៌មានបន្ថែមទៀតមែនទេ?

សូមពិភាក្សាជាមួយគ្រូពេទ្យទូទៅរបស់អ្នក ប្រសិនបើអ្នកមានសំណួរណាមួយអំពីការចាក់វ៉ាក់សាំងបង្កាជំងឺគ្រុនផ្តាសាយធំ។ អ្នកក៏អាចទូរសព្ទទៅកាន់ 13 HEALTH តាមរយៈលេខ 13 43 25 84 ហើយនិយាយទៅកាន់គិលានុបដ្ឋាយិកា។ សូមស្នើសុំអ្នកបកប្រែ បើសិនជាអ្នកត្រូវការ។ អ្នកអាចស្វែងយល់បន្ថែមទៀតអំពីវ៉ាក់សាំងបង្កាជំងឺផ្តាសាយ និងធនធាននានាជាភាសារបស់អ្នក នៅទីនេះ។

Search for

Vaccination Matters

Queensland Government